# ខ្សែជីវិតតាមរយៈចក្ខុវិញ្ញាណរបស់យើង



សមាគមមណ្ឌលព័ត៌មានកម្មករ WIC និងគម្រោងវាយនភណ្ឌបទដ្ឋានសង្គមនៅក្នុងតំបន់អាស៊ី (SLSG) របស់ GIZ កាលពីថ្ងៃអាទិត្យ ទី១១ ខែមីនា ឆ្នាំ២០១៨ បានបើកពិធីសម្ពោធតាំងពិព័រណ៍រូបភាពដែលជាស្នាដៃរបស់កម្មការិនីរោងចក្រកាត់ដេរ ក្រោមចំណងជើងថា «ខ្សែជីវិតតាមរយៈចក្ខុវិញ្ញាណរបស់យើង» នៅមណ្ឌលវប្បធម៌អាឡឺម៉ង់-កម្ពុជា (មេត្តា ហៅស៍)។

កម្មការិនី ០៩រូបមកពីរោងចក្រខុសៗគ្នាបានទទួលការបណ្ដុះបណ្ដាលដោយអ្នកថតរូប គឺលោកស្រី អ៊ែនទ្រា ឌីហ្វេនបាច (Adrea Diefenbach) ដើម្បីបង្កើតនូវកម្រងរូបភាព ដែលឆ្លុះបញ្ចាំង អំពីស្ថានភាពជីវិតរបស់ពួកគេផ្ទាល់ បើកបង្ហាញនូវការមើលឃើញរបស់ពួកគេអំពីពិភពលោកនិងផ្ដិតយករូបភាពអំពីការគិត អារម្មណ៍ និងក្ដីស្រមៃ។

នៅក្នុងឱកាសនេះដែរ លោកស្រី ម៉ាក ច័ន្ទស៊ីថា អ្នកសម្របសម្រួលសមាគមមណ្ឌលព័ត៌មានកម្មករបង្ហាញថា មូលហេតុដែលសមាគមមណ្ឌលព័ត៌មានកម្មករធ្វើការសហការជាមួយគម្រោង SLSG ព្រោះគម្រោងនេះបានផ្ដល់ឱកាសឲ្យកម្មការិនីបានរៀនសូត្រ អនុវត្តផ្ទាល់ និងបានបង្ហាញនូវស្នាដៃរបស់ពួកគាត់។ ទោះបីជាកម្មការិនីមមាញឹកនឹងការងារយ៉ាងណា ប៉ុន្តែពួកគាត់មានទេពកោសល្យ និងសមត្ថភាពនៅពេលដែលអ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងវិស័យនេះផ្ដល់ឱកាស និងការគាំទ្រដល់ពួកគាត់។

នៅក្នុងពិធីនេះ កម្មការិនី ០៦រូបបានធ្វើបទបង្ហាញពីស្នាដៃរូបភាពរបស់ខ្លួនយ៉ាងក្បោះក្បាយ។ ដើម្បីញ៉ាំងកម្មវិធីឲ្យកាន់តែល្អប្រសើរឡើង ក្រោយពីបញ្ចប់ការធ្វើបទបង្ហាញអំពីរូបភាព កម្មការិនីទាំង ០៦រូបបានច្រៀងចម្រៀងដែលជាស្នាដៃនិពន្ធរបស់កម្មការិនីម្នាក់នៅក្នុងចំណោមកម្មការិនីទាំងនោះ ដែលបទចម្រៀងមានចំណងជើងថា «នេះឬជីវិតកម្មករ?» ដែលបានបង្ហាញយ៉ាងច្បាស់អំពីស្ថានភាពពិតរបស់កម្មការិនីរោងចក្រ។

នៅក្នុងពិធីសម្ពោធនេះមានការអញ្ជើញចូលរួមពីភ្ញៀវប្រមាណ១០០នាក់ ក្នុងនោះមានកម្មការិនីកម្មកររោងចក្រកាត់ដេរ ក្រុមគ្រួសារ និងមិត្តភក្ដិពួកគាត់តំណាងម្ចាស់ផ្លាកសហជីព និងអង្គការមួយចំនួនទៀត៕



បោះពុម្ពផ្សាយដោយ
អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org



ព្រឹត្តិបត្រ
ចេញផ្សាយខែមេសា ឆ្នាំ២០១៨
ទំព័រកម្មករ
ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ
លេខទី ៩

# ពីព្យួរកិច្ចសន្យាការងារឈានទៅផ្ដាច់កិច្ចសន្យាការងារ រួចបិទសង្វាក់ផលិតកម្ម និង សហគ្រាស

រោងចក្រ អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣) បានបញ្ចប់កិច្ចសន្យាការងារកម្មការិនី កម្មករ ទាំងស្រុងនៅខែមេសា ឆ្នាំ២០១៨ ទោះបីជាមានកម្មការិនី កម្មករមួយចំនួននៅទាមទារការងារធ្វើក៏ដោយ។

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ រោងចក្រនេះបានជូនដំណឹងដល់កម្មការិនី កម្មករទាំងអស់នៅអគារA ឲ្យបើកប្រាក់ឈ្នួលផ្ដាច់កិច្ចសន្យាការងារចាប់ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៧។ ដោយឡែកកម្មកររោងចក្រអគារផ្សេងទៀត នៅមានការងារធ្វើជាធម្មតា។

លុះដល់ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៨ រោងចក្រជូនដំណឹងព្យួរការងាររយៈពេលមួយខែពេញដល់កម្មការិនី កម្មករទាំងអស់ដែលមានចំនួនសរុប ១៦៩០នាក់ ក្រោមហេតុផលគ្មានការបញ្ជាទិញ។ ប៉ុន្តែកម្មការិនីកម្មករមួយចំនួនមិនយល់ព្រមក្នុងការព្យួរការងារនេះ ដោយពួកគេអះអាងថា ការងារនៅតែមានធ្វើកាលពីខែធ្នូ ឆ្នាំ២០១៧ ដូច្នេះហេតុផលគ្មានការបញ្ជាទិញ គឺមិនសមស្របនោះទេ។ ដោយឡែកកម្មការិនីកម្មករមួយចំនួនបាននាំគ្នាតវ៉ាឲ្យថៅកែរោងចក្រទូទាត់សំណងផ្ដាច់កិច្ចសន្យា ពីព្រោះពួកគេបារម្ភខ្លាចរោងចក្របិទទ្វារដោយមិនបានទទួលសំណង ខណៈកម្មការិនី កម្មករអគារ A បានផ្ដាច់កិច្ចសន្យាហើយទទួលបានសំណងរួចជាស្រេច។

ដោយសារមានការតវ៉ារបស់កម្មការិនីកម្មករចំពោះថៅកែរោងចក្រ ដូច្នេះទើបនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ អធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានមកប្រជុំជាមួយតំណាងខណ្ឌមានជ័យ តំណាងក្រុមហ៊ុន អ៊ឹម វ៉េ (សាខា៣) តំណាងកម្មករ និងកម្មករដើម្បីដោះស្រាយបញ្ហាកម្មករស្នើសុំទូទាត់សំណងផ្ដាច់កិច្ចសន្យាការងារ។ នៅក្នុងកិច្ចប្រជុំនេះដែរ តំណាងខាងក្រុមហ៊ុនបានសន្យាថា ប្រសិនបើ ខែមីនា ឆ្នាំ២០១៨ រោងចក្រនៅតែគ្មានការងារផ្ដល់ដល់កម្មការិនីកម្មករ នោះរោងចក្រនឹងយល់ព្រមផ្ដល់នូវសំណងផ្ដាច់កិច្ចសន្យាតាមច្បាប់ ប៉ុន្តែអំឡុងពេលនេះរោងចក្រស្នើសុំព្យួរការងារកម្មការិនីកម្មករ។

បន្ទាប់ពីការព្យួរការងាររយៈពេលមួយខែ នៅដើមខែកុម្ភៈ ឆ្នាំ២០១៨ រោងចក្របានតម្រូវឲ្យកម្មការិនីកម្មករជាន់ទី២ ផ្នែកម៉ុកឈប់សំរាកបំណាច់ឆ្នាំ សម្រាប់កម្មការិនីកម្មករដែលគ្មានបំណាច់ឆ្នាំត្រូវព្យួរការងាររយៈពេលកន្លះខែ។ បន្ទាប់ពីកម្មការិនីកម្មករជាន់ទី២ ចូលធ្វើការវិញ កម្មការិនីកម្មករជាន់ទី៣ ត្រូវព្យួរការងារម្ដង។

អំឡុងពេលកម្មការិនីកម្មករព្យួរការងាររដ្ឋបាលរោងចក្រ បានចុចឈ្មោះហៅកម្មការិនី កម្មករមួយចំនួនទៅជួបចចារ ដើម្បីទូទាត់សំណងផ្ដាច់កិច្ចសន្យា។ កត្តានេះបានធ្វើឲ្យកម្មការិនី កម្មករកាន់តែផ្ទុះការតវ៉ាទាមទារឲ្យថៅកែរោងចក្រទូទាត់សំណងផ្ដាច់កិច្ចសន្យាឲ្យកម្មការិនី កម្មករទាំងអស់គ្នា។

នៅថ្ងៃទី២៦-២៧ ខែកុម្ភៈ ២០១៨ រោងចក្របានជួបប្រជុំជាមួយកម្មការិនី កម្មករដើម្បីជូនដំណឹងពីការប្ដូរអគារ ការងារដោយរោងចក្រតម្រូវឲ្យកម្មការិនីកម្មករប្ដូរពីអគារ៥ជាន់ ទៅអគារ A ប៉ុន្តែកម្មការិនីកម្មករមិនយល់ព្រមនោះទេ ព្រោះពួកគេយល់ថា ប្រសិនបើនៅតែធ្វើតាមការចាត់ចែងរបស់ក្រុមហ៊ុននោះនឹងគ្មានការទូទាត់សំណងផ្ដាច់កិច្ចសន្យានោះទេ។





នៅដើមខែមីនា ឆ្នាំ២០១៨ រោងចក្រសហជីព បានប្រជុំជាមួយកម្មការិនីកម្មករដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមានឡើង។ លុះដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ រោងចក្របានសម្រេចទូទាត់សំណងផ្ដាច់កិច្ចសន្យាដល់កម្មការិនីកម្មករទាំងអស់ទៅតាមច្បាប់ស្ដីពីការងារ។

ដោយឡែក កម្មការិនីមួយចំនួនមិនបានយល់ព្រមក្នុងការផ្ដាច់កិច្ចសន្យានោះទេ ដោយពួកគេទាមទាររោងចក្រឲ្យផ្ដល់ការងារពួកគេធ្វើ។ អំឡុងពេលទាមទារការងារធ្វើនេះ កម្មការិនីបានសង្កេតឃើញរោងចក្របានរើសកម្មករចាស់ៗមកធ្វើការតាមផ្នែកវិញ ដោយពួកគេធ្វើការទទួលប្រាក់ឈ្នួលទៅតាមម៉ោង (ក្នុងមួយម៉ោង ៥០០០រៀល) និងធ្វើការតាមអាណត្តិ (មួយអាណត្តិមាន២ខែ) ដូច្នេះពួកគេនៅតែរំពឹងថា រោងចក្រនឹងអាចផ្ដល់ការងារឲ្យពួកគេធ្វើបាន។ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ អ្នកគ្រប់គ្រងរោងចក្របានជួបប្រជុំកម្មការិនីដែលទាមទារការងារធ្វើនោះដោយរោងចក្រអះអាងថា រោងចក្រគ្មានលទ្ធភាពបន្តដំណើរការរោងចក្រនេះទេ ដូច្នេះសហ

» តទៅទំព័រ ៣

# តើនរណាជាអ្នកទទួលខុសត្រូវ?
## តើច្បាប់ស្តីពីការងារត្រូវអនុវត្តយ៉ាងដូចម្តេច?



សេដ្ឋកិច្ចជាតិមួយផ្នែកធំបានមកពីវិស័យឧស្សាហកម្មវាយនភណ្ឌកាត់ដេរ ចុះហេតុអ្វីក៏សង្គម និងអ្នកពាក់ព័ន្ធទាំងអស់ហាក់ដូចជាមិនសូវឲ្យតម្លៃ មិនយកចិត្តទុកដាក់ខ្វាយខ្វល់ពីសុខភាព សុវត្ថិភាពចំណូលចំណាយ និងមិនលើកទឹកចិត្តដល់អ្នកដែលធ្វើការនៅក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌកាត់ដេរ។

ជារៀងរាល់ឆ្នាំតែងតែមានការដំឡើងប្រាក់ឈ្នួលជូនកម្មករ ទន្ទឹមនឹងការដំឡើងប្រាក់ឈ្នួលនេះ ក៏មានការប្រែប្រួលលក្ខខណ្ឌការងារនៅក្នុងរោងចក្រផងដែរ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៤ ក្រុមហ៊ុន យ៉ូ ដា បានផ្តាច់កិច្ចសន្យាការងាររបស់កម្មករទាំងអស់ពីកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ទៅជាកិច្ចសន្យាការងារដែលមានថិរវេលាកំណត់វិញ។ លើសពីនេះក៏មានការកាត់បន្ថយចំនួនកម្មករ មានការរំសាយក្រុមចូលគ្នាជាបន្តបន្ទាប់។

នៅចុងឆ្នាំ២០១៧ ក្រុមហ៊ុន យ៉ូ ដា មានការរំសាយក្រុមបន្តទៀត និងមិនរើសកម្មករថ្មីចូលទេ តែបើរើសចូលវិញគឺឲ្យធ្វើជាកម្មករបណ្តែត ឬកម្មករទទួលប្រាក់ឈ្នួលតាមថ្ងៃ។ ឯចំនួនផលិតផលក៏កើនឡើងធ្វើឲ្យកម្មករត្រូវធ្វើការថែមម៉ោង បើកម្មករមិនព្រមថែមម៉ោងក៏មានការគំរាមបញ្ឈប់មិនបន្តកុងត្រាឲ្យ។ កម្មការិនី យឹន ស្រីអូន បានឲ្យដឹងថា៖ «បញ្ហាទាំងអស់នោះផងដែរ វាបានកើតឡើងចំពោះរូបខ្ញុំផ្ទាល់ និងមិត្តផ្សេងទៀត ព្រោះតែមានចិត្តចង់បន្តការសិក្សារបស់ខ្លួនអត់មានប្រាក់ខំប្រឹងធ្វើការផង រៀនផង សុំចេញម៉ោង៤ ត្រូវបានប្រធានខ្មែរ ប្រធានចិនស្តីថា គំរាមគំហែងរករឿងស្ទើររាល់ថ្ងៃ ពេលខ្លះដាក់ច្បាប់ក៏ប្រធានមិនឲ្យ ធ្វើឲ្យខ្ញុំភ័យខ្លាច»។

ចូលដល់ឆ្នាំ២០១៨ ប្រាក់ឈ្នួលកម្មករត្រូវបានដំឡើងដល់១៧០ដុល្លារ ហើយរដ្ឋាភិបាលក៏បានជួយសម្រួលឲ្យនិយោជកបង់វិភាគទាន ប ស ស ១០០ភាគរយដល់កម្មករ ព្រមទាំងផ្តល់អត្ថប្រយោជន៍មួយចំនួនទៀតដូចជា កំណត់ថ្លៃទឹក មិនអនុញ្ញាតឲ្យម្ចាស់ផ្ទះដំឡើងថ្លៃជួល និងការប្រើប្រាស់រថយន្តក្រុងសាធារណៈ ដោយឥតបង់ថ្លៃជាដើម។ នេះជារឿងមួយគួរឲ្យត្រេកអរសម្រាប់កម្មករ តែផ្ទុយទៅវិញកម្មការិនីកម្មករទាំងអស់នៅក្នុងរោងចក្រ យ៉ូ ដា ប្រមាណជាង៥០០នាក់ និងរោងចក្រសាខា២ទៀតរបស់ យ៉ូដា ត្រូវបាត់បង់ការងារ។ នៅដើមខែមករា ឆ្នាំ២០១៨ ពេលដែលថៅកែរោងចក្រត្រូវបើកប្រាក់ឈ្នួលខែធ្នូឲ្យកម្មករ ថៅកែបែរជាជំពាក់កម្មករម្នាក់ ៣០ដុល្លារ ក្រោមហេតុផលថា រោងចក្រអ៊ីហ្វាដែលជាសាខារបស់ យ៉ូ ដា ត្រូវបានចោរចូលគាស់ យកឯកសារធនាគារ និងលុយមួយចំនួន។ លុះដល់ថ្ងៃទី១៥ ខែមករា ទើបបើកឲ្យកម្មករគ្រប់ចំនួន។ នៅក្នុងខែមករាឆ្នាំដដែល ក្រុមហ៊ុនបានឲ្យកម្មករឈប់សម្រាកទទួលបានប្រាក់ឈ្នួល ៥០ភាគរយជាបន្តបន្ទាប់ ព្រមទាំងពន្យាពេលបើកលុយឲ្យទៅកម្មករ។ ជាទម្លាប់រោងចក្របើកលុយយឺតបំផុតត្រឹមថ្ងៃទី៧ នៃខែបន្ទាប់ តែដើមឆ្នាំ២០១៨នេះបែរជាត្រូវបើកនៅថ្ងៃទី១០។ ប៉ុន្តែមិនទាន់ដល់ថ្ងៃទី១០ផង នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ ស្រាប់តែថៅកែរត់បាត់ មិនទទួលខុសត្រូវចំពោះកម្មករ ធ្វើឲ្យកម្មករជ្រួលច្របល់។

សហជីព និងក្រសួងការងារបានសម្របសម្រួលថា កម្មករមានជម្រើសពីរ ទី១ លក់សម្ភារៈក្នុងរោងចក្រ តាមប្រព័ន្ធតុលាការ ប៉ុន្តែត្រូវប្រើពេលយូរនៅរ៉ាំរ៉ៃមិនងាយដោះស្រាយទេ។ ទី២ លក់ក្រៅប្រព័ន្ធតុលាការ កម្មករឆាប់បានលុយ និងឆាប់បានទៅរកការងារថ្មីទៀតមិនបាច់ខាតពេលវេលាយូរ។

កម្មករពិតជាត្រូវការប្រាក់ ពួកគាត់យល់ព្រមលក់ក្រៅប្រព័ន្ធតុលាការ ដើម្បីយកលុយខ្លះមកដោះស្រាយបញ្ហាជីវភាព។ ទឹកប្រាក់សរុបដែលបានពីការលក់សម្ភារៈគឺមានចំនួន១៥ម៉ឺន៥ពាន់ដុល្លារ។ សហជីពទទួលបានទឹកប្រាក់ ១០ភាគរយនៃចំនួនទឹកប្រាក់សរុបនេះ។ ចំណែកឯកម្មករម្នាក់ៗទទួលបានប្រាក់៦៦ភាគរយនៃប្រាក់ឈ្នួលគោលចុងក្រោយរបស់គាត់តែប៉ុណ្ណោះ។ កម្មការិនីស្រីអូនបានបង្ហាញថា៖ «ខ្ញុំមិនទទួលយកលុយ៦៦ភាគរយនោះទេ ព្រោះខ្ញុំឈឺចាប់ណាស់ ខំធ្វើការរាប់ឆ្នាំចុងបញ្ចប់អត់ន័យ កម្មករទទួលបានត្រឹមតែ៦៦ភាគរយនៃប្រាក់ឈ្នួលចុងក្រោយ ខ្ញុំក៏លំបាកដូចបងប្អូនកម្មករដទៃទៀតដែរ ខ្ញុំគ្មានអ្នកទីពឹងត្រូវរ៉ាប់រងលើខ្លួនឯង ណាត្រូវចំណាយបង់ថ្លៃសាលា បង់ថ្លៃផ្ទះជួល ទឹក ភ្លើង អាហារហូបចុក សម្ភារៈសិក្សា មធ្យោបាយធ្វើដំណើរ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន បើទោះជាខ្ញុំព្រមទទួលយកលុយ៦៦ភាគរយនោះមកក៏មិនអាចជួយឲ្យខ្ញុំបានប្រសើរឡើងដែរ ខ្ញុំត្រូវការសំណងត្រឹមត្រូវតាមច្បាប់»។

បន្ទាប់ពីមានការបិទរោងចក្រ កម្មការិនីកម្មករ យ៉ូ ដា ជួបបញ្ហាលំបាកជាច្រើន កម្មការិនី កម្មករ ដែលមានវ័យចំណាស់ត្រូវបាត់បង់ការងារមិនអាចទៅធ្វើការងាកន្លែងថ្មីទៀតបាន ខ្លះទៀតស្វះស្វែង ដើររកការងារគ្រប់ទីកន្លែង ត្រូវទៅធ្វើការងារនៅទីឆ្ងាយពីកន្លែងដែលស្នាក់នៅធ្វើឲ្យមានការចំណាយប្រាក់កាន់តែច្រើន ខ្លះត្រូវបានប្តូរការងារពីកន្លែងមួយទៅកន្លែងមួយទៀត

» តនៅទំព័រ ៣





« **តើនរណាជាអ្នកទទួល...**

ហើយអ្នកខ្លះក៏ត្រឡប់ទៅស្រុកកំណើតវិញ ខ្លះទៀតក៏ចូលធ្វើការតាមសិប្បកម្ម ដែលមិនគោរពលក្ខខណ្ឌការងារត្រឹមត្រូវ។

បច្ចុប្បន្ននេះ បន្ទាប់ពីកម្មករមានការយល់ដឹងអំពីសិទ្ធិ និងច្បាប់តាមរយៈមណ្ឌលសំចតព្រៃទា កម្មករ យ៉ូ ដា មួយចំនួនបានកៀងគរគ្នា ប្រមូលស្នាមមេដៃ ដើម្បីធ្វើសំណើរទាមទារសិទ្ធិ និងអត្ថប្រយោជន៍ដែលខ្លួនត្រូវទទួលបានតាមផ្លូវច្បាប់។

យោងតាមច្បាប់ស្តីពីការងារ មាត្រា៧៣ មាត្រា៧៥ មាត្រា១៦៦ មាត្រា១៦៧ មាត្រា៨៩ និងមាត្រា៩១ កម្មករមានសិទ្ធិទទួលបានសំណង៥ចំណុច នៅពេលរោងចក្របិទ និងផ្តាច់កិច្ចសន្យារួមមាន៖ ប្រាក់ជួសឲ្យការជូនដំណឹងមុន ប្រាក់បំណាច់បណ្តេញចេញ ប្រាក់សោហ៊ុយជំងឺចិត្ត ប្រាក់ជួសការឈប់សំរាកប្រចាំឆ្នាំ និងប្រាក់ខែចុងក្រោយ។

កម្មការិនីកម្មកររោងចក្រ យ៉ូ ដា មួយចំនួននេះនឹងបន្តជជែកគ្នាកៀងគរ រួចហើយនឹងធ្វើការជាមួយក្រសួងការងារ និងអ្នកពាក់ព័ន្ធ ដើម្បីទទួលបាននូវដំណោះស្រាយសមរម្យ ជាពិសេសកម្មការិនីកម្មករសង្ឃឹមថា ពួកគេនឹងទទួលបានសំណងតាមច្បាប់៕

# កម្មការិនី និងទិវានារីអន្តរជាតិ



ដើម្បីចូលរួមអបអរទិវានារីអន្តរជាតិ ឆ្នាំ២០១៨ សម្ព័ន្ធបងប្អូនស្រីបានចូលរួមសហរៀបចំជាមួយអង្គការដៃគូនានាដូចជា នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ បានសហរៀបចំប្រារព្ធទិវានារីអន្តរជាតិនៅមជ្ឈមណ្ឌល សហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC) ក្រោមប្រធានបទ «ភាពខ្លាំងរបស់ស្ត្រី» ក្នុងគោលបំណងរំលឹក និងបង្ហាញអំពីការផ្តល់តម្លៃដល់ភាពជោគជ័យ ការតស៊ូ ការខិតខំប្រឹងប្រែង និងទេពកោសល្យរបស់ស្ត្រីនៅគ្រប់វិស័យ។

លុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ សម្ព័ន្ធបងប្អូនស្រីក៏បានរួមចំណែកក្នុងការរៀបចំអបអរទិវានារី អន្តរជាតិក្រោមប្រធានបទ «កិច្ចគាំពារសង្គម និងសុខុមាលភាពប្រជាពលរដ្ឋ» ដែលប្រព្រឹត្តទៅនៅសាលាអន្តរទ្វីបអាមេរិកាំង (AIS) ។ ដោយនៅក្នុងវិស័យវាយនភណ្ឌកាត់ដេរមានស្ត្រីដែលជាកម្មការិនីរហូតដល់ជាង៩០ភាគរយ ទិវានារីអន្តរជាតិគឺជាឱកាសសម្រាប់កម្មការិនីក្នុងការចូលរួមចែករំលែកបទពិសោធន៍ បង្កើតទំនាក់ទំនងបណ្តាញ និងសាមគ្គីភាពជាមួយស្ត្រីៗដែលមកពីវិស័យផ្សេងៗ និងស្ថាប័ននានា៕



« **ពីព្យួរកិច្ចសន្យាការងារ...**

គ្រាសទាំងមូលត្រូវបិទទ្វារ។ ដូច្នេះកម្មការិនីក៏បានស្នើសុំមើលលិខិតបិទទ្វារសហគ្រាសដែលចេញដោយក្រសួងការងារ។

លុះមកដល់ដើមខែមេសា ឆ្នាំ២០១៨ រោងចក្របានបិទប្រកាសលិខិតបិទទ្វាររោងចក្រ ដែលរោងចក្របានដាក់ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែពួកគេពុំបានឃើញលិខិតឆ្លើយតបពីក្រសួងការងារទាក់ទងជាមួយលិខិតបិទរោងចក្រ អ៊ឹម វ៉េ (សាខា៣)នេះទេ។ យ៉ាងណាក៏ដោយពួកគេនៅតែមិនអស់ចិត្តដោយសារក្រុមហ៊ុនផ្តាច់កិច្ចសន្យាការងាររបស់ពួកគេ ដោយគុណប្រាក់បំណាច់បណ្តេញចេញចំនួនតែ ១២ឆ្នាំ បើទោះជាពួកគេធ្វើការនៅរោងចក្រនេះរយៈពេល ១៧ឆ្នាំ ដល់ ២១ឆ្នាំក៏ដោយ។ រោងចក្រអះអាងថា ក្រុមហ៊ុនគុណអតីតភាពការងារទៅតាមច្បាប់ស្តីពីការងារមាត្រា៨៩។ កម្មការិនី នឹងទទួលសំណងនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨។

ចំពោះកម្មការិនីកម្មករនៅអគាស្វ័យប្រវត្តិវិញ បានទទួលបានសំណងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ កម្មការិនី កម្មករផ្នែកខាល់អំបោះបានទទួលសំណងនៅខែមេសា ឆ្នាំ២០១៨។

ទោះបីជារោងចក្របានប្រកាសបិទទ្វាររោងចក្រ ប៉ុន្តែកម្មការិនី កម្មករនៅតែសង្កេតឃើញថា រហូតមកដល់ខែមេសានេះនៅក្នុងរោងចក្រ នៅតែមានកម្មការិនីកម្មករកិច្ចសន្យាបណ្តែតផ្នែកបោកគក់ធ្វើការងារ ហើយឡានដឹកទំនិញចេញចូលរោងចក្រនៅតែដំណើការ។

គួររំលឹកដែរថា នៅដើមឆ្នាំ២០១៨ រោងចក្រមួយចំនួនបានបិទទ្វារ ហើយថៅកែបានគេចខ្លួន ដោយមិនបានគិតគូរបើកប្រាក់ខែនិងសំណងឲ្យកម្មការិនី កម្មករ។ យោងតាមគេហទំព័រថ្មីៗបានឲ្យដឹងថា រោងចក្រ៩ ត្រូវបានបិទទ្វារដែលរួមមាននៅខេត្តកណ្តាល១ កំពង់ស្ពឺ៣ និងនៅរាជធានីភ្នំពេញ៥ ហើយរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់ក្នុងការចំណាយថវិកាផ្ទាល់ខ្លួន ក្នុងទូទាត់ប្រាក់ឈ្នួលនិងសំណងដល់កម្មការិនីកម្មករនៅរោងចក្រ ដែលបិទទ្វារទាំង០៩នេះ៕